## ព្រឹត្តិបត្របច្ចេកទេស លេខ ៧៧

# ការគ្រប់គ្រងថ្នាលបណ្ដុះកូនឈើ

### ការរៀបចំថង់

នៅពេលធ្វើការបណ្ដុះកូនឈើ ការពិចារណាឬអនុវត្តតាមជាជំហានៗឲ្យបានត្រឹមត្រូវ គឺជាការសំខាន់ សូមមើលឧទាហរណ៍ខាងក្រោម(រូបភាពទី១) ៖

១. ដីច្រកក្នុងថង់មិនបានពេញល្អ មាត់ថង់រមូរចូល ធ្វើឲ្យការស្រោចទឹកមិនបានសព្វល្អ ។
២. ឬសកូនឈើរួញ នាំឲ្យងាយដួលរលំដោយសារខ្យល់បោកបក់នៅពេលវាធំ ។
៣. កូនឈើស្ទួងមិនចំកណ្ដាលថង់ ។
៤. ដីច្រកក្នុងថង់មិនបានណែនល្អ ។
៥. ដីក្នុងថង់ណែនជ្រុល ។
៦. រៀបចំលាយដីមិនបានល្អ ។
៧. កូនឈើក្នុងថង់ដុះបានល្អបំផុត ។

រូបភាពទី១




**ចំណាំ៖** ល្បាយដីគួរមាន ១ភាគ៣ជាកំប៉ុស្ដិ៍ ១ភាគ៣ជាដីខ្សាច់ និង ១ភាគ៣ជាដីនៅក្នុងភូមិ ។

### ការសម្អាតស្មៅ



សូមស្រោចទឹកថ្នាលឲ្យបានជោគ មុននឹងបោចស្មៅ ។ ដកស្មៅដោយប្រុងប្រយ័ត្នដោយដៃរបស់អ្នក ហើយស្រោចទឹកម្ដងទៀតបន្ទាប់ពីដកស្មៅរួច ។

រៀបចំថង់កូនឈើដែលបានច្រកដីរួច និងស្រោចទឹកវា ២សប្ដាហ៍ មុនពេលដាក់គ្រាប់ចូលទៅក្នុងថង់ ដើម្បីឲ្យស្មៅដុះចេញមក ហើយធ្វើការដកស្មៅចេញដោយមិនមានការរំខានដល់កូនឈើ ។

### ការរៀបតាមលំដាប់ថ្នាក់



រៀបកូនឈើតាមលំដាប់ថ្នាក់(តូច ធំ) ធ្វើឲ្យប្រសើរឡើងដល់ការលូតលាស់របស់កូនឈើ ។ ក្នុងពេលជាមួយគ្នានោះត្រូវយកកូនឈើដែលក្រិន មានជម្ងឺ និងទន់ខ្សោយចេញ ហើយជ្រើសរើសយកតែកូនឈើណាដែលមានសុខភាពល្អ និងរឹងមាំ ដើម្បីយកមកពង្រឹងដើមនិងដាំ ។ វិធីសាស្ត្រនេះនឹងធ្វើឲ្យអត្រារស់នៅក្រោយពេលដាំមានកម្រិតអតិបរមា ។

## ការពង្រឹងដើម



ការរពង្រឹងដើមនៃកូនឈើ ជាដំណើរការបន្សាំកូនឈើពីលក្ខខ័ណ្ឌងាយស្រួលនៅក្នុងថ្នាល ទៅលក្ខខ័ណ្ឌលំបាកជាក់ស្តែងស្រដៀងនឹងតំបន់ព្រៃរិចរឹលដែលត្រូវដាំឈើឡើងវិញ ។ បើសិនជាកូនឈើទាំងនោះមិនរឹងមាំ និង មិនធន់ទ្រាំទៅនឹងលក្ខខ័ណ្ឌក្តៅស្ងួតក្រោមកំដៅព្រះអាទិត្យនៅតំបន់ដាំកូនឈើទេ កូនឈើនឹងអន់ខ្លាំងហើយងាប់ក្រោយពេលដាំ ។

ប្រហែលជា៣ខែមុនពេលដាំ ត្រូវផ្ទេរកូនឈើដែលត្រូវដាំពីរងបណ្តុះកូនឈើ ទៅកន្លែងមួយផ្សេងទៀតនៅក្នុងទីធ្លានៃថ្នាល ហើយម្តងបន្តិចៗ បន្ថយគម្របម្លប់ដើម្បីឲ្យកូនឈើស៊ាំនឹងពន្លឺថ្ងៃ និងស្រោចទឹកឲ្យបានញឹកញាប់ ។ នៅខែចុងក្រោយមុនពេលដាំ កូនឈើទាំងអស់នោះត្រូវនៅស្ថិតនៅកណ្តាលវាលក្រោមពន្លឺថ្ងៃពេញលេញ ។

## ការក្រៃឫសកូនឈើ

កាត់ឫសកូនឈើដែលដុះចេញខាងក្រៅថង់ផ្លាស្ទិក ដើម្បី ការពារកូនឈើកុំឲ្យចាក់ឫសចូលក្នុងដី ដែលធ្វើឲ្យពិបាកដកយកមកដាំ ។ សូមចាប់ផ្តើមពិនិត្យឫសកូនឈើពេលវាមានអាយុបាន ៣ខែ ។



## គម្លាតកូនឈើ




រៀបចំកូនឈើឲ្យមានគម្លាតពីថង់មួយទៅថង់មួយទៀត ធំជាងមុន ។ គម្លាតធំធ្វើឲ្យពន្លឺព្រះអាទិត្យចូលបានគ្រប់គ្រាន់ ដើម្បីសម្លាប់បាក់តេរី និងជម្ងឺផ្សិត ជួយធ្វើឲ្យកូនឈើមានសុខភាពល្អ ដើមធំ ហើយរឹងមាំជាងមុន និង ចៀសវាងមិនឲ្យកូនឈើខូចទ្រង់ទ្រាយដើមរបស់វា ។

**កម្ពុជាហាវែស**

ផ្ទះលេខ ៤៦ ផ្លូវ ៣១០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន
ក្រុងភ្នំពេញ
ទូរស័ព្ទ ០២៣ ៩៩៦ ៤១៩
harvest@fintrac.com

ព្រឹត្តិបត្រនេះរៀបចំឡើងក្រោមការឧបត្ថម្ភពីប្រជាពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID)។ ខ្លឹមសារនៅក្នុងឯកសារនេះគឺជាការទទួលខុសត្រូវទាំងស្រុងរបស់ក្រុមហ៊ុនហ្វីនត្រាក់ Fintrac Inc. និងមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID ឬ រដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ ។